ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
សាលាភូមិន្ទរដ្ឋបាល
លេខ.....៣៤.......ស.ភ.រ

ថ្ងៃ ពុធ ៩ រោច ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០២២

**សូមគោរពជូន**
**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**និងប្រធានគ្រប់ក្រសួង ស្ថាប័ន**

**កម្មវត្ថុ ៖** សេចក្តីជូនដំណឹងស្តីពីការស្ទង់មតិប្រមូលធាតុចូលលើតម្រូវការបណ្តុះបណ្តាលមន្ត្រីរាជការ នៅសាលាភូមិន្ទរដ្ឋបាល។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា សាលាភូមិន្ទរដ្ឋបាលមានបេសកកម្មបណ្តុះបណ្តាលមន្ត្រីរាជការមកពីបណ្តាក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយរៀបចំការបណ្តុះបណ្តាលរយៈពេលវែង មធ្យម និងខ្លីទៅតាមវគ្គនីមួយៗ ដែលមានកំណត់ក្នុងបេសកកម្មរបស់សាលា។ ក្នុងគោលបំណងបំពេញសេចក្តីត្រូវការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យកាន់តែមានភាពឆ្លើយតប ប្រសិទ្ធភាព និងផលិតភាពខ្ពស់បន្ថែមទៀត ខ្ញុំបាទសូមគោរពស្នើសុំ **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាជួយសម្រួលក្នុងការផ្សព្វផ្សាយនូវសេចក្តីជូនដំណឹងស្តីពីការស្ទង់មតិប្រមូលធាតុចូលអំពីតម្រូវការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីរាជការ ដូចបានគោរពជូនភ្ជាប់មកជាមួយ ដោយការបំពេញទិន្នន័យសំណួរក្នុងប្រព័ន្ធអនឡាញតាមរយៈតំណភ្ជាប់ ឬការស្កេនQRកូដ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាពិនិត្យសម្រេចផ្សព្វផ្សាយដ៏ខ្ពង់ខ្ពស់។

សូម **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**ជ.រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**
**និងជាប្រធានក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល**
**នាយកសាលា**

**យក់ ប៊ុនណា**

បណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប**

អាសយដ្ឋាន : អគារលេខ ១៧ វិថីឧកញ៉ាឃ្លាំងមឿង (៤៦៦) រាជធានីភ្នំពេញ , ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 89 55 31 55 / 015 94 42 77
អ៊ីម៉ែល : cea.rsa@gmail.com គេហទំព័រ : www.era.cambodia.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

**សាលាភូមិន្ទរដ្ឋបាល**

លេខ......៣៣.......ស.ភ.រ

# សេចក្ដីជូនដំណឹង

យោងតាមភាពចាំបាច់ក្នុងការអនុវត្តបេសកកម្មនៃការបណ្ដុះបណ្ដាលមន្ត្រីរាជការមកពីបណ្ដាក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របតាមគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សរបស់រាជរដ្ឋាភិបាលកម្ពុជា សាលាភូមិន្ទរដ្ឋបាលនឹងពិនិត្យរៀបចំកម្មវិធីសិក្សារបស់សាលាឱ្យកាន់តែមានភាពឆ្លើយតប ប្រសិទ្ធភាព គុណភាព និងផលិតភាពខ្ពស់។ អាស្រ័យហេតុនេះ សាលាភូមិន្ទរដ្ឋបាល សូមគោរពអញ្ជើញ **សម្ដេច ឯកឧត្ដម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា** ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការបម្រើការងារតាមបណ្ដាក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ មេត្តាចូលរួមជួយបំពេញនូវកម្រងសំណួរតាមប្រព័ន្ធអនឡាញ ដើម្បីស្ទង់មតិប្រមូលធាតុចូលនូវសេចក្ដីត្រូវការបណ្ដុះបណ្ដាលសមត្ថភាពមន្ត្រីរាជការតាមរយៈតំណភ្ជាប់ https://bit.ly/3Iq0c58 ឬការស្កេនQRកូដខាងក្រោមនេះ។

សាលាភូមិន្ទរដ្ឋបាលសូមគោរពជម្រាបជូន **សម្ដេច ឯកឧត្ដម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា** ជាថ្នាក់ដឹកនាំនិងមន្ត្រីរាជការបម្រើការងារតាមបណ្ដាក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ មេត្តាជ្រាបថា ការចូលរួមផ្ដល់មតិយោបល់តាមរយៈការស្ទង់មតិខាងលើនេះ គឺជាទិន្នន័យធាតុចូលមានសារៈសំខាន់បំផុត ក្នុងការធ្វើទំនើបកម្មកម្មវិធីសិក្សានិងការធ្វើនវានុវត្តន៍វគ្គបណ្ដុះបណ្ដាលថ្មីៗបន្ថែមទៀត ដែលឆ្លើយតបនឹងសេចក្ដីត្រូវការពិតប្រាកដរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

អាស្រ័យដូចនេះ សូម **សម្ដេច ឯកឧត្ដម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា** មេត្តាជ្រាបជាព័ត៌មាន និងចូលរួមការស្ទង់មតិប្រមូលធាតុចូលឱ្យបានគ្រប់ៗគ្នាតាមការគួរ។

ថ្ងៃពុធ ៩ រោច ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០២២

**សាលាភូមិន្ទរដ្ឋបាល**

https://bit.ly/3Iq0c58


អាសយដ្ឋាន : អគារលេខ ១៧ វិថីឧកញ៉ាញ៉ឹកជូឡុង (៤៦៦) រាជធានីភ្នំពេញ , ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 89 55 31 55 / 015 94 42 77

អ៊ីម៉ែល : cea.rsa@gmail.com គេហទំព័រ : www.era.cambodia.gov.kh